**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**សាលាខេត្តកណ្ដាល**

លេខ:..០៦០...ស.ស.រ

កណ្ដាល, ថ្ងៃទី..២៤.. ខែ..តុលា.. ឆ្នាំ២០១៤

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពខេត្ត

## អភិបាលខេត្តកណ្ដាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៦ ចុះថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តកណ្ដាល ។

-យោងប្រកាសលេខ ៤២៧៤ ប្រ.ក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្តកណ្ដាល ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។

-យោងតាមសេចក្ដី ណែនាំលេខ ០១៤ សណន/គ.ជ.វ.វ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្ដីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត-ក្រុង ។

-យោងលិខិតលេខ ៣០ គ.ជ.អ.ប ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្ដីពីការរៀបចំឡើងវិញនូវក្រុមការងារគណនេយ្យភាពរាជធានី-ខេត្ត។

-យោងសេចក្ដីជូនដំណឹង ០២៩ ស.ជ.ណ/គ.ជ.អ.ប ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្ដីពី ការរៀបចំសមាសភាពក្រុមការងារគណនេយ្យភាពរាជធានី-ខេត្ត ឡើងវិញ និងបន្តដំណើរការប្រមូល និងដោះស្រាយពាក្យបណ្ដឹង ។

-យោងសេចក្ដីកំណត់លេខ ០៣០ សកណ/គ.ជ.អ.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្ដីពីរបៀបរបបធ្វើការងាររបស់ក្រុមការងារគណនេយ្យភាពជាតិ ។/.

-សេចក្ដីសម្រេចលេខ ....... ស.ស.រ ចុះថ្ងៃទី...... ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាខេត្តកណ្ដាល ស្ដីពីការកែសម្រួលសមាសភាពក្រុមការងារគណនេយ្យភាពខេត្ត ។

-យោងតាមតម្រូវការចាំបាច់របស់ខេត្តកណ្ដាល ។

## សម្រេច

**ប្រការ ១៖** បង្កើតក្រុមគាំទ្រ ក្រុមការងារគណនេយ្យភាពខេត្ត ដើម្បីធ្វើជាលេខាធិការក្នុងការជួយអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមការងារគណនេយ្យភាពខេត្ត (ក.គ.ខ) កណ្ដាល ។

**ប្រការ ២៖** ក្រុមគាំទ្រនេះ មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-លោក | ថន | សុវណ្ណា | នាយករងរដ្ឋបាលខេត្ត | ជាប្រធាន |
| ២-លោក | ទ្រី | ប៊ុនប៉ាង | នាយករងទីចាត់ការផែនការ-វិនិយោគ | ជាអនុប្រធាន |
| ៣-លោក | ដាវ | បុត្ររង្សី | អនុប្រធានការិ.ច្បាប់ និងសុវត្ថិភាពសាធារណៈ | ជាលេខាធិការ |
| ៤-លោក | គីម | ចាន់បញ្ញោ | អនុប្រធានការិយាល័យគ្រប់គ្រងអភិវឌ្ឍន៍សំណង់ | ជាសមាជិក |
| ៥-លោកស្រី | អ៊ុន | សុគន្ធា | មន្ត្រីទីចាត់ការអន្តរវិស័យ | ជាសមាជិក |

**ប្រការ ៣៖** ដើម្បីជួយអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ ក.គ.ខ ក្រុមគាំទ្រនេះមានភារកិច្ចដូចតទៅ ៖

-ជួយរៀបចំ និងពិនិត្យផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់ក្រុមការងារគណនេយ្យភាពខេត្ត (ក.គ.ខ) ។

-ជួយតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើផែនការសកម្មភាព និងដំណើរការអនុវត្តការងាររបស់មន្ត្រី ជំនួយការក្រុមការងារគណនេយ្យភាពខេត្ត ដើម្បីលើកអនុសាសន៍ជូន ក.គ.ខ សម្រេច ។

-ជួយរៀបចំសេចក្ដីព្រាងលិខិតបទដ្ឋាន និងគោលការណ៍ណែនាំនានា សម្រាប់ការអនុវត្តការងាររបស់ ក.គ.ខ ក្នុងការដោះស្រាយរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹងភាពមិនប្រក្រតីនៃការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.អ.ប និងមូលនិធិឃុំ សង្កាត់ និងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

-ចូលរួមសេចក្ដីព្រាងយុទ្ធសាស្ត្រ និងសម្ភារៈ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដូចជាផ្ទាំងរូបភាព សន្លឹកប័ណ្ណព័ត៌មាន រូបភាពវីដេអូខ្លីៗសម្រាប់អប់រំផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ រៀបចំវេទិកាសាធារណៈ និងមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ។

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើដំណើរការអនុវត្តយុទ្ធសាស្ត្រ ផ្សព្វផ្សាយព័ត៌មានរបស់មន្ត្រីជំនួយការក្រុមការងារគណនេយ្យភាពខេត្ត ដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ។

-ទំនាក់ទំនងជាប្រចាំ ជាមួយមន្ត្រីជំនួយការក្រុមការងារគណនេយ្យភាពខេត្ត អំពីការអនុវត្ត សកម្មភាព និង ផ្តល់ព័តិមានត្រឡប់ ដើម្បីពង្រឹងការបំពេញការងារ តួនាទីរបស់មន្ត្រីទាំងនោះ អោយកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

-រៀបចំកិច្ចប្រជុំរបស់ ក.គ.ខ ដោយមានកិច្ចការជាមួយមន្ត្រីជំនួយការក្រុមការងារគណនេយ្យភាពខេត្ត ។

-ពិនិត្យរបាយការណ៍រីកចម្រើន ស្តីពីការអនុវត្តការងាររបស់មន្ត្រីជំនួយការក្រុមការងារគណនេយ្យភាពខេត្ត ដើម្បីដាក់ជូន អង្គប្រជុំ ក.គ.ខ ពិនិត្យសម្រេចជាចុងក្រោយមុនផ្ញើទៅថ្នាក់ជាតិ ។

-រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូរអភិវឌ្ឍន៍ និងសង្គមស៊ីវិលអំពីគោលការណ៍ និងនីតិវិធីនានា ដែលពាក់ព័ន្ធនឹងដំណើរការ ក.គ.ខ តាមការចាំបាច់ និងតាមការណែនាំពី ក.គ.ជ ។

-សម្របសម្រួលជាមួយមន្ទីរ ស្ថាប័នពាក់ព័ន្ធ ក្នុងការគាំទ្រការអន្តរាគមន៍ និងដោះស្រាយរាល់បញ្ហាផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងកិច្ចការរបស់ក្រុមការងារគណនេយ្យភាពខេត្ត ។

-អនុវត្តគោលការណ៍ណែនាំ ឬអនុសាសន៍ផ្សេងៗ ដែល ក.គ.ខ បានដាក់ចេញអោយអនុវត្ត ។

**ប្រការ ៤÷** ប្រធានក្រុមគាំទ្រត្រូវចាត់ចែង និងដឹកនាំក្រុមគាំទ្រដើម្បីធានាការអនុវត្តតួនាទី និងភារកិច្ចដូចចែងក្នុងប្រការ៣ ។ ក្នុងករណីអវត្តមាន ប្រធានក្រុមគាំទ្រត្រូវផ្ទេរសិទ្ធអោយអនុប្រធាន ។ ប្រធានក្រុមគាំទ្រត្រូវកំណត់របៀបរបបធ្វើការងាររបស់ក្រុម និងបែងចែកភារកិច្ចជាក់ស្តែង ដល់សមាជិកនីមួយៗនៃក្រុមគាំទ្រ ។

**ប្រការ ៥÷** ក្រុមគាំទ្រនៃ ក.គ.ខ ត្រូវមានមន្ត្រីចំនួន ០៣រូបដែលត្រូវចូលរួមពេញលេញ ក្នុងការអនុវត្តកម្មវិធីជាតិ ០៣ឆ្នាំដំបូង (ផអ៣) ។ តួនាទី និងភារកិច្ចរបស់មន្ត្រី ០៣រូបនេះ ត្រូវកំណត់ក្នុងលក្ខខណ្ឌការងារដាច់ដោយឡែក ។

**ប្រការ ៦÷** ការិយាល័យក្រុមគាំទ្ររបស់ ក.គ.ខ ត្រូវបំពាក់នូវឧបករណ៍ សម្ភារៈការិយាល័យ ទូរស័ព្ទ អ៊ីមែលអោយបានគ្រប់គ្រាន់ ដើម្បីធានាការអនុវត្តភារកិច្ចរបស់ខ្លួនអោយមានប្រសិទ្ធភាព ។

**ប្រការ ៧÷** សមាជិកក្រុមការងារគណនេយ្យភាពខេត្តកណ្តាល និងលោក លោកស្រី ដូចបានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

**អភិបាលខេត្ត និងជាប្រធានក្រុមការងារគណនេយ្យភាពខេត្ត**

ផៃ ប៊ុនឈឿន

**ចម្លងជូន ៖**

-លេខាធិការដ្ឋាន គ.ជ.អ.ប

-ក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ

-ក្រុមការងារគណនេយ្យភាពខេត្ត

**"ដើម្បីជូនជ្រាប"**

-ដូចក្នុងប្រការ ២ **"ដើម្បីអនុវត្ត"**

-ឯកសារ-កាលប្បវត្តិ